សូមមេត្តាផ្ញើឯកសារតាមប្រៃសណីយ៍មកអាស័យដ្ឋាន៖
01 ផ្លូវ 96 សង្កាត់ វត្តភ្នំ
ខ័ណ្ឌ ដូនពេញ រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា

សេចក្តីណែនាំចំពោះបេក្ខជនសុំទិដ្ឋាការ
មិនមែនអន្តោប្រវេសន៍ ប្រភេទគូជណ្តឹង

ការិយាល័យកុងស៊ុលយើងខ្ញុំ បានទទួលសំណុំរឿងដែលធានាលោកអ្នកឲ្យក្លាយជាបេក្ខជនមានសិទ្ធិសុំទិដ្ឋាការមិនមែនអន្តោប្រវេសន៍-ប្រភេទគូដណ្តឹង ទៅសហរដ្ឋអាមេរិកដើម្បីរៀបការជាមួយអ្នកធានា។ ដើម្បីត្រៀមខ្លួនសំរាប់ការសម្ភាសន៍ជាមួយមន្ត្រីកុងស៊ុល សូមលោកអ្នកអានសេចក្តីណែនាំនេះដោយយកចិត្តទុកដាក់និងធ្វើតាមការណែនាំដូចខាងក្រោមនេះ។

ជំហានដំបូង: សូមបំពេញឯកសារដែលមានភ្ជាប់ជូនមកជាមួយដូចខាងក្រោម រួចសូមរួសរាន់ផ្ញើឯកសារទាំងនេះមកការិយាល័យយើងខ្ញុំវិញ៖

- DS-230 Part 1 (ពាក្យសុំ ស្តីពីប្រវត្តិរូបសង្ខេបរបស់បេក្ខជន)
- I-134 (ពាក្យធានាផ្នែកហិរញ្ញវត្ថុ) របស់អ្នកធានា
- OF-169 (សេចក្តីណែនាំចំពោះបេក្ខជនសុំទិដ្ឋាការអន្តោប្រវេសន៍)

ការិយាល័យកុងស៊ុលមិនអាចដំណើរការសំណុំរឿងរបស់អ្នកបានទេ បើមិនបានទទួលឯកសារទាំងអស់ខាងលើនេះ។ សូមផ្ញើឯកសារទាំងនេះក្នុងកញ្ចប់តែមួយតាមរយៈប្រៃសណីយ៍មកអាស័យដ្ឋាន #01 ផ្លូវ 96 សង្កាត់វត្តភ្នំ ខ័ណ្ឌដូនពេញ រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា។ ការិយាល័យកុងស៊ុលនឹងមិនទទួលឯកសារទាំងនេះដោយផ្ទាល់ដៃ ពីបេក្ខជនឬអ្នកធានាទេ។ បន្ទាប់ពីបានទទួលឯកសារទាំងអស់នេះ ការិយាល័យកុងស៊ុលនឹងផ្តល់ជូនអ្នកនូវថ្ងៃណាត់សម្ភាសន៍។ អ្នកអាចរកមើលថ្ងៃណាត់សម្ភាសន៍របស់អ្នកនៅលើគេហទំព័រនៃស្ថានទូតសហរដ្ឋអាមេរិកប្រចាំប្រទេសកម្ពុជាគឺ៖ http://cambodia.usembassy.gov/immigrant_visas.html ។ បើក្នុងរយៈពេល 2 ទៅ 3 ខែ លោកអ្នកនៅតែរកមិនឃើញ លេខសំណុំរឿង របស់អ្នកក្នុងបញ្ជីណាត់សម្ភាសន៍ទេ សូមលោកអ្នកផ្ញើឯកសារទាំងនេះជាថ្មីទៀត។

ជំហានទីពីរ: លោកអ្នកត្រូវមានឯកសារដែលមានចុះក្នុងបញ្ជីខាងក្រោមនេះរួចជាស្រេច មុនថ្ងៃមកសម្ភាសន៍។ លោកអ្នក**មិនត្រូវផ្ញើ**ឯកសារទាំងនេះមកការិយាល័យកុងស៊ុលទេ ប៉ុន្តែត្រូវកាន់មកនៅថ្ងៃសម្ភាសន៍។

☐ 1- **លិខិតឆ្លងដែន**៖ លិខិតឆ្លងដែនដែលមានសុពលភាពប្រើប្រាស់ក្នុងការធ្វើដំណើរទៅសហរដ្ឋអាមេរិក ហើយដែលមានសុពលភាពយ៉ាងតិច ៦ ខែ ។ កូនៗរបស់អ្នកគឺត្រូវតែមានលិខិតឆ្លងដែនដោយឡែករៀងៗខ្លួន ទោះបីជាអាយុប៉ុន្មានក៏ដោយ។

☐ 2- **សំបុត្រកំណើត**៖ លោកអ្នកត្រូវបង្ហាញសំបុត្រកំណើតច្បាប់ដើម និងច្បាប់ចម្លង(photo copy)

☐ 3- **រូបថត**៖ រូបថត២សន្លឹក (ទំហំ 2 x 2 អ៊ីញ ឬ 5 x 5 ស.ម) ថតចំពីមុខ ផ្ទៃក្រោយពណ៌ស។ សូមអានសេចក្តីណែនាំពីការថតរូបដែលមានភ្ជាប់មកជាមួយ។

☐ 4- **លិខិតបញ្ជាក់ពីភាពនៅលីវ ឬ មេម៉ាយ ឬពោះម៉ាយ**៖ រាល់បេក្ខជនសុំទិដ្ឋាការ ប្រភេទគ្ងដណ្ដឹងទាំងអស់ គឺតំរូវអោយមានលិខិតដែលចេញដោយឃុំ ឬ សង្កាត់ បញ្ជាក់ថាខ្លួននៅលីវ ឬបិតនៅក្នុងភាពមេម៉ាយ ឬ ពោះម៉ាយ។

☐ 5-**សាលក្រមលែងលះឬលិខិតមរណភាព**៖ បេក្ខជនដែលធ្លាប់រៀបការ ត្រូវតែមានភស្តុតាងនៃការបញ្ចប់ អាពាហ៍ពិពាហ៍មុនៗដូចជា លិខិតមរណភាព ឬសាលក្រមលែងលះស្ថាពរ។

☐ 6- **ភស្តុតាងនៃទំនាក់ទំនង**៖ អាចជាលិខិតស្នាមផ្សេងៗ សំបុត្រទាក់ទងគ្នា រូបថត និងភស្តុតាងផ្សេងៗ ដែលអ្នកគិតថាជាភស្តុតាងនៃទំនាក់ទំនងរបស់អ្នកជាមួយអ្នកធានានិងអ្នកដែលពាន់ព័ន្ធ។

☐ 7-**ពិនិត្យសុខភាព**៖ រាល់បេក្ខជនសុំទិដ្ឋាការប្រភេទគ្ងដណ្ដឹងទាំងអស់ទោះបីជាអាយុប៉ុន្មានក៏ដោយ ត្រូវតែ ពិនិត្យសុខភាពអោយបានរួចរាល់។
សូមអានសេចក្ដីណែនាំនៃការពិនិត្យសុខភាពដែលមានភ្ជាប់មកជាមួយ។

☐ 8- **ព្រឹត្តិប័ត្រថ្កោលទោស**៖ រាល់បេក្ខជនសុំទិដ្ឋាការដែលមានអាយុចាប់ពី 16 ឆ្នាំឡើងទៅ គឺត្រូវតែមាន ព្រឹត្តិប័ត្រថ្កោលទោសដែលចេញដោយអាជ្ញាធរនៃប្រទេសកំណើតខ្លួន ដែលបានស្នាក់នៅយ៉ាងតិច ៦ខែ ចាប់តាំងពីខ្លួនមានអាយុ 16 ឆ្នាំ ហើយក៏តំរូវអោយមានប្រសិនបើលោកអ្នកធ្លាប់ស្នាក់នៅប្រទេសក្រៅ លើសពី១ឆ្នាំ។ ព្រឹត្តិប័ត្រថ្កោលទោសក៏ត្រូវតែ មានចំពោះបេក្ខជនដែលធ្លាប់ត្រូវបានចាប់ខ្លួនទោះក្នុងករណី អ្វីក៏ដោយ ដោយមិនគិតពីរយៈពេលនៃការ ស្នាក់នៅក្នុងប្រទេសនោះឡើយ។ ព្រឹត្តិប័ត្រថ្កោលទោសនោះ ត្រូវតែអាចបញ្ជាក់បានក្នុងរយៈពេលនៃការស្នាក់នៅសរុបក្នុងប្រទេសនោះ។ ព្រឹត្តិប័ត្រថ្កោលទោសដែល ចេញដោយអាជ្ញាធរនៃប្រទេសដែលអ្នកកំពុងរស់នៅត្រូវតែទើបចុះកាលបរិច្ឆេទថ្មីៗ។
ព្រឹត្តិប័ត្រថ្កោលទោសគឺលិខិតដែលចេញដោយអាជ្ញាធរ ដែលបង្ហាញពីរបាយការណ៍ពាក់ព័ន្ធនិងបេក្ខជន និមួយៗរួមមានរាល់បទល្មើសនិងមូលហេតុនៃការចាប់ខ្លួននិងការដោះលែង។ នៅ**កម្ពុជា** ព្រឹត្តិប័ត្រ ថ្កោលទោសត្រូវបានចេញដោយក្រសួងយុត្តិធម៌ ដែលមាន អាស័យដ្ឋាន៖ #240 ផ្លូវសម្ដេចសុធារស រាជធានីភ្នំពេញ(ទល់មុខព្រះបរមរាជវាំង)។ សំរាប់ប្រទេស ផ្សេងទៀត សូមចូលមើលគេហទំព័រ៖ http://travel.state.gov/visa/fees/fees_3272.html ។

☐ 9- **លិខិតបញ្ជាក់ការងារកងទ័ព**៖ លិខិតបញ្ជាក់នេះ គឺតម្រូវឲ្យបេក្ខជន ស្នើសុំពីនាយកដ្ឋាន អង្គភាព ឬ ការិយាល័យដែលបេក្ខជនកំពុងឬធ្លាប់បំរើការងារ។ លិខិតនេះគឺជាកំណត់ត្រា ពីប្រវត្តិការងារទាំងស្រុង ដែលបេក្ខជនធ្លាប់បំពេញការងារ។ លិខិតនេះក៏ត្រូវបញ្ជាក់ផងដែរ រាល់កំហុសការងារ ឬបទល្មើសដែល ត្រូវបានផ្ដន្ទាទោសដោយតុលាការយោធា។

☐ 10- **កំណត់ត្រាតុលាការនិងពន្ធនាគា**៖ បេក្ខជនដែលបានប្រព្រឹត្តបទល្មើសត្រូវតែមានលិខិត កំណត់ត្រា ដែលបានបញ្ជាក់ពីរាល់តុលាការនិងពន្ធនាគារ ទោះបីជាទោសនោះត្រូវបានទទួលការលើកលែង។

☐ 11- ពាក្យសុំទំរង់ **DS-156K** ៖ មានតែបេក្ខជនចំបងម្នាក់ប៉ុណ្ណោះ ដែលត្រូវបំពេញពាក្យសុំនេះ។ បំពេញ ហើយ សូមកុំចុះហត្ថលេខា។ កូនៗរបស់អ្នកមិនតំរូវឲ្យបំពេញទេ។

- ☐ 12- ពាក្យសុំទំរង់ **DS-156 ៖** សូមបំពេញពត៌មានរបស់បេក្ខជនដោយផ្ទាល់នៅក្នុងពាក្យសុំទំរង់ DS-156 ដែលជាពាក្យសុំទិដ្ឋាការបែបអេឡិចត្រូនិកនៅលើគេហទំព័រ http://evisaforms.state.gov តែម្យ៉ាងគត់។ សូមព្រីនចេញមក ហើយបិទរូបថតទំហំ 5x5 ស.ម. និងចុះហត្ថលេខា។ ទំព័រទី3នៃពាក្យសុំនេះ នឹងមានគំនូសខ្មៅ ឆ្នូត។ (Barcode) ដែលផ្ទុកនូវទិន្នន័យរបស់វា។ ប្រសិនបើកូនរបស់អ្នកមានបំណងសុំទិដ្ឋាការជាមួយអ្នក នោះកូន។ត្រូវតែមានពាក្យសុំនេះរៀង។ខ្លួន។

- ☐ 13- **ពាក្យសុំទំរង់ DS-157** ៖ សំរាប់តែបេក្ខជនជាបុរសដែលមានអាយុពី 16 ដល់ 45ឆ្នាំ។ លោកបំពេញហើយសូមកុំចុះហត្ថលេខា។

- ☐ 14- **ការបកប្រែឯកសារ**៖ រាល់ឯកសារដែលមិនមែនជាភាសារអង់គ្លេស ត្រូវតែមានភ្ជាប់មកជាមួយ នូវឯកសារបកប្រែជាភាសារអង់គ្លេស។ ឯកសារដែលបានបកប្រែ ត្រូវតែបកប្រែដោយកន្លែង ឬភ្នាក់ងារដែលមានការទទួលខុសត្រូវចំពោះមុខច្បាប់ គឺត្រូវមានឈ្មោះ ហត្ថលេខា និងទីកន្លែងភ្នាក់ងារបកប្រែ។ ឯកសារដែលបានបកប្រែគឺត្រូវតែបកប្រែចេញពីឯកសារដើមទាំងស្រុង ហើយគ្មានការបន្ថែមបន្ថយឬកែតម្រូវ។ ការិយាល័យកុងស៊ុលនឹងមិនទទួលយកឯកសារដែលបកប្រែនៅលើឯកសារដើមតែមួយ ជាមួយគ្នានោះទេ។ សូមបេក្ខជនទាំងអស់យកចិត្តទុកដាក់ខ្ពស់លើរាល់ឯកសារដែលបានបកប្រែ។ សូមធ្វើការផ្ទៀងផ្ទាត់ដោយខ្លួនឯងឲ្យហើយ មុននិងទទួលយកពីកន្លែងឬភ្នាក់ងារបកប្រែឯកសារ ដូចជាឈ្មោះ ថ្ងៃខែឆ្នាំកំណើត ទីកន្លែងកំណើត កាលបរិច្ឆេទ ទីកន្លែង និងលេខចុះបញ្ជី ព្រមទាំងអត្ថន័យផ្សេង។ ព្រោះការិយាល័យកុងស៊ុលនឹងបដិសេធរាល់ឯកសារបកប្រែទាំងឡាយណាដែលមិនត្រឹមត្រូវ។

បេក្ខជនសុំទិដ្ឋាការជាប្រភេទគ្រួដណ្ដឹងទាំងអស់ត្រូ**វបង់ប្រាក់**សំរាប់សម្ភាសន៍នៅថ្ងៃសម្ភាសន៍។ ពត៌មានអំពីតំលៃ សូមចូលមើលក្នុងគេហទំព័រ៖ http://travel.state.gov រួចស្វែងរកតារាងតំលៃពី Fees for Visa services ។ ការបង់លុយសុទ្ធត្រូវតែបង់ជារូបិយប័ណ្ណរបស់សហរដ្ឋអាមេរិក។

លោកអ្នកមិនចាំបាច់មកសាកសួរពត៌មាននៅស្ថានទូតអំពីសំណុំរឿងរបស់អ្នកទេ ប៉ុន្តែលោកអ្នកត្រូវជូនដំណឹងមកស្ថានទូត ប្រសិនបើស្ថានភាពរបស់អ្នកមានការប្រែប្រួលដូចជា ផ្លាស់ប្តូរអាស័យដ្ឋាន លោកអ្នកទើបតែរៀបអាពាហ៍ពិពាហ៍ អ្នកធានាបានទទួលមរណភាព ឬក៏អ្នកមានកូនដែលទើបតែកើត តាមរយ:អ៊ីមេលគឺ ivphnompenh@state.gov ។ សូមកុំផ្ញើឯកសារពាក់ព័ន្ធនិងរឿងទាំងនេះមកស្ថានទូត បើស្ថានទូតមិនតម្រូវឲ្យអ្នកធ្វើដូច្នេះ។

ឯកសារភ្ជាប់៖

- DS-230 Part 1(ពាក្យសុំទិដ្ឋាការរបស់បេក្ខជនអន្ដោប្រវេសន៍)
- DS-156K (ពាក្យសុំសម្រាប់បេក្ខជនសុំទិដ្ឋាការដែលជាគ្រួដណ្ដឹង)
- DS-157 (ពាក្យសុំសម្រាប់បេក្ខជនជាបុរស អាយុពី 16 ដល់ 45ឆ្នាំ)
  អ្នកអាចទាញយកពាក្យសុំខាងលើទាំងនេះពីគេហទំព័រ៖ http://travel.state.gov
- I-134 (ពាក្យធានាផ្នែកហិរញ្ញវត្ថុ) របស់អ្នកធានា។ អាចទាញយកពីគេហទំព័រ៖ www.uscis.gov
- I-864P (គោលការណ៍ណែនាំស្ដីពីបន្ទាត់នៃភាពក្រីក្រ)។ អាចទាញយកពីគេហទំព័រ៖ www.uscis.gov
- សេចក្ដីណែនាំអំពីការពិនិត្យសុខភាព
- សេចក្ដីណែនាំអំពីការថតរូប

ខ្ញុំសូមបញ្ជាក់ថា ខ្ញុំបានអានដោយយកចិត្តទុកដាក់និងយល់ច្បាស់នូវរាល់សេចក្តីណែនាំខាងលើទាំងអស់ ហើយខ្ញុំនឹងរៀបចំរាល់ឯកសារដែលពាក់ព័ន្ធនិងខ្ញុំតាំងពីចំនុចលេខ 1 រហូតដល់លេខ 13 ព្រមទាំងបាន គូសសញ្ញា (✓) បញ្ជាក់នៅក្នុងប្រអប់ផង។ ខ្ញុំក៏បានយល់យ៉ាងច្បាស់ថា គ្មានការធានាណាមួយដែលថា ខ្ញុំប្រាកដជានឹងទទួលបានទិដ្ឋាការទេ ហើយខ្ញុំក៏បានដឹងដែរថា ខ្ញុំមិនត្រូវបោះបង់ការងារ ការសិក្សា លក់ទ្រព្យសម្បត្តិ ឬរៀបចំសម្រាប់ការធ្វើដំណើរជាមុនណាមួយឡើយ លុះត្រាតែខ្ញុំបានទទួលទិដ្ឋាការក្នុងដៃ។

- ☐ ខ្ញុំសុំទិដ្ឋាការតែម្នាក់ឯង
- ☐ ខ្ញុំសុំទិដ្ឋាការជាកូនរបស់ខ្ញុំឈ្មោះ៖

_____

_____

_____

_____

កាលបរិច្ឆេទ

_____

លេខសំណុំរឿង(ប្រសិនបើមាន)

_____

ហត្ថលេខានិង

_____

ឈ្មោះបេក្ខជនចំបង

_____

អាស័យដ្ឋានបច្ចុប្បន្ន

_____

សូមចងចាំថា

- លោកអ្នកនឹងមិនទទួលបានការណាត់សម្ភាសន៍ណាមួយទេ ប្រសិនបើរាល់ឯកសារដែលការិយាល័យកុងស៊ុលតម្រូវឲ្យផ្ញើមកទាំងនោះ មិនទាន់បានទទួល។ សូមអានសេចក្តីណែនាំខាងលើត្រង់ ជំហានទី១។

- កុំផ្ញើឯកសារផ្សេងៗមកស្ថានទូត ប្រសិនបើស្ថានទូតមិនបានតម្រូវឲ្យធ្វើ។
- អ្នកមានកាតព្វកិច្ចត្រូវជូនដំណឹងមកស្ថានទូត រៀងរាល់ពេលអាស័យដ្ឋានរបស់អ្នកមានការផ្លាស់ប្តូរ។ ប្រសិនបើមិនដូច្នោះទេ ការចុះឈ្មោះរបស់អ្នកសំរាប់ការរស់នៅសហរដ្ឋនឹងត្រូវលប់ចោល។